## រាជបណ្ឌិត្យសភាកម្ពុជា

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## - ភាគទី៥ - វគ្គទី២

អត្ថបទចងក្រងដោយៈ លោកស្រី ស៊ិន ច័ន្ទអមរា
មន្ត្រីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា




ទីតាំងប្រយុទ្ធគ្នារវាងកងទ័ពបារាំងនិងអាល្លឺម៉ង់នៅឡាម៉ានន៍ នៅជិតក្រុងបារីស ដើមខែកញ្ញា ឆ្នាំ១៩១៤
The Battle of the Marne, La bataille de la Marne (1914)

នៅក្នុងភាគទី៥ វគ្គទី២នេះ យើងសូមរៀបរាប់បន្តនូវសុន្ទរកថារបស់លោកចៅហ្វាយក្រុងភ្នំពេញ ក្នុងពិធីសម្ពោធ«ផ្ទាំងរំឭក»( Plaque commémorative) អំពីការស្នាក់នៅក្នុងសាលាក្រុងភ្នំពេញនៃលោកសេនាប្រមុខ ហ្សូហ្វ ( Maréchal Joffre ) កាលពីខែធ្នូ ឆ្នាំ១៩២១ ដែលមានខ្លឹមសារដើមនិងការកែសម្រួលមួយចំនួនដូចខាងក្រោម៖

មូលហេតុដែលរាជការក្រុមមឿង( សាលាក្រុង )អញ្ជើញអស់លោក អស់អ្នក មកក្នុងថ្ងៃនេះគឺដើម្បីមករៀបចំបោះ«ផ្ទាំងរំឭក»នេះឯងហើយ។

មនុស្សជំនាន់ក្រោយ ដែលមិនបានភិតភ័យនឹងចម្បាំងក្នុងគ្រានោះនឹងមានសេចក្ដីភ្លេចឆាប់ណាស់ ចំពោះស្នាដៃរបស់អ្នកដែលនាំឱ្យបានជ័យជម្នះនេះ។ ប្រសិនបើមិនធ្វើ«ផ្ទាំងរំឭក»នេះទេ ដល់យូរៗទៅកូនចៅរបស់យើងនឹងភ្លេចអំពី«ចម្បាំងឡាម៉ានន៍» (Guerre de la Marne) និងឈ្មោះមេទ័ពម្នាក់ដែលនាំឱ្យមានជោគជ័យនៅទីនោះ។ ដូចនេះមិនត្រូវឱ្យមានសេចក្ដីអកតញ្ញូនៅក្នុងចិត្តបារាំងសេសដែលនៅស្រុកខ្មែរ និង ក្នុងចិត្តអាណាប្រជានុរាស្ត្រខ្មែរឡើយ។ «ផ្ទាំងរំឭក»ធ្វើអំពីសំរិទ្ធដែលបោះនៅត្រង់រុក្ខវិថីសុព (Avenue Joffre) នៅចំពោះមុខលោកសេនាប្រមុខតែម្ដងនោះ ជារបស់តឹកតាង១ ធ្វើមុនគេបង្អស់ដើម្បីឱ្យដឹងអង្វែងតទៅមុខ ថាលោកសេនាប្រមុខបានអញ្ជើញមកក្រុងភ្នំពេញ។ «ផ្ទាំងរំឭក» ធ្វើអំពីថ្មកែវ១ផ្ទាំង ដែលបោះនៅបន្ទប់សម្រាប់អ្នកទាំងពួងនៅផ្ទះរាជការក្រុមមឿង( សាលាក្រុង )នោះ នឹងនាំឱ្យរឹតតែចាំពីលោកដែលបានអញ្ជើញមកក្រុងភ្នំពេញនេះថែមទៀត។

ខ្ញុំសូមជម្រាប អស់លោកអស់អ្នកជ្រាបថា មូលហេតុដែលរាជការក្រុមមឿងក្រុងភ្នំពេញ ធ្វើក្នុងគ្រាឥឡូវនេះមិនមែនធ្វើឱ្យតែមេទ័ពធំតែម្នាក់ឯង ដោយបាននាំកងទ័ពទៅតយុទ្ធឥតរុញរាទេ។ ការធ្វើនេះគឺធ្វើឱ្យទាំងពួកកងទ័ពនោះផង ដោយបានជួយសង្គ្រោះនគរឱ្យរួចបានដោយសារតែមានចិត្តក្លាហាន។ យើងពល់គ្នាគ្មាននរណាហើយដែលមិនចាំអំពីខ្សែលួស( ទូរលេខ ) ពីប្រទេសបារាំងដែលបានបញ្ជូនដំណឹងស្ដីពីការព្រួយរបស់មេដឹកនាំបារាំងមកឱ្យយើងដឹងថាទ័ពយើងចេះតែថយបន្តិចម្ដងៗ និងអំពីការព្រួយរបស់យើង ដោយបានទទួលដំណឹងនេះ។ ប៉ុន្តែយើងនៅតែមិនបាត់សេចក្ដីសង្ឃឹម។




ផែនទីបង្ហាញអំពីព្រែកឡាម៉ានន៍ ដែលជាដៃទន្លេសែននៅខាងកើតក្រុងប៉ារីស
Marne River/ Rivière de la Marne

ក្រោយមកដំណឹងថាបានគ្រាន់បើនៅព្រែកឡាម៉ានន៍ (Rivière de la Marne) ហើយឃើញសេចក្ដីបង្គាប់ពីលោកសេនាប្រមុខសុព ដូច្នេះថា៖ យើងកំពុងតែចូលតយុទ្ធដើម្បីឱ្យនគរនឹងបានជ័យជម្នះលើពួកអាល្លឺម៉ង់។ យើងត្រូវតែរំឭកអ្នកទាំងអស់គ្នាថាក្នុងគ្រានេះអ្នកមិនត្រូវគិតពីរឿងដកថយក្រោយទេ ត្រូវខំវាយនិងខំដេញសង្កុញពួកខ្មាំង ឱ្យវាថយទៅក្រោយវិញឱ្យពេញទំហឹង។ ពួកទាហានដែលខំប្រឹងទៅមុខទៀតមិនរួច ត្រូវតែខំក្រាញនៅៗ ទីតាំងដែលខ្លួនយកបាន ហើយមិនត្រូវថយទេ ត្រូវស៊ូឱ្យទាល់តែអស់ជីវិតនៅទីនោះ។ ក្នុងគ្រាឥឡូវនេះតែមានធ្វើខុសហើយ នឹងអនុញ្ញាតទោសមិនបានសោះឡើយ ហើយឮដំណឹងថាទ័ពខ្មាំងវាបាត់រត់តគ្រាត់តគ្រាយ[1]តាមផ្លូវ ដែលវាចូលមកកាលវាកំពុងនៅមានជ័យ។

ស្រុកបារាំងតាំងពីនោះមកបានរួចខ្លួនហើយៗ បានរៀបចំតយុទ្ធធន់យូរដែលមានមកក្រោយៗទៀតបានដោយពួកទាហាននោះនៅរាំងដូចជារបងដែក១គ្មាននរណាទម្លាយបានសោះតាំងអំពីនោះរៀងមក។

ខ្ញុំសូមជម្រាបអស់លោកអស់អ្នកជ្រាប ថាលោកមេកងទ័ពដែលមានកេរ្តិ៍ឈ្មោះល្បីនោះ មិនដែលធ្វើឱ្យមានកំហុស, មិនដែលបាត់សង្ឃឹម និងមិនដែលគិតថាបារាំងមិនក្លាហាន និងមិនតស៊ូនោះទេ។

---

[1] តគ្រាត់តគ្រាយ ជាភាសានិយាយនៅសម័យនោះដែលមានន័យស្មើនឹងរប៉ាត់រប៉ាយ។

ម្យ៉ាងទៀត លោកមើលយល់អំពីស្ថានភាពបានច្បាស់លាស់ និងចេះរៀនចំយុទ្ធវិធីជាបន្ត។ គឺលោកសេនាប្រមុខនេះហើយដែលចេះបញ្ជាឱ្យកងទ័ពដកថយដល់ឡាមានន៍( la Marne ) និងឱ្យទប់ទល់នៅទីនោះហើយចេះរកពេលវាយបកវិញរហូតដល់បានជោគជ័យ។ លោកសេនាប្រមុខសុព ដែលល្បីឈ្មោះនេះឯងគួរតែយើងចាំកុំភ្លេចសោះពីលោកដែលបានអញ្ជើញមកសំណាក់នៅផ្ទះរាជការក្រុមមឿងនេះ។

នៅលើផ្ទាំងថ្មកែវនេះមានអក្សររំឭកអំពីលោកដែលបានអញ្ជើញមកក្រុងភ្នំពេញ ដើម្បីរំឭកគុណលោក។

អក្សរនៅលើផ្ទាំងថ្មនេះមានខ្លឹមសារទាំងស្រុងដូចខាងក្រោម៖

*«ក្នុងវាងដែលមានកិច្ចធុរៈដំណើរមកជារាជការក្នុងស្រុកទិសបូព៌[2]ចុងបំផុត "អិស្សត្រែមអូរីយ៉ង"[3]*

***នោះលោកម៉ារេសាល់សុព***

*ដែលមានជ័យជម្នះក្នុងចម្បាំងឡាម៉ានន៍ បានអញ្ជើញមកសំណាក់នៅទីផ្ទះរាជការក្រុមមឿងនេះ*

*នៅថ្ងៃ១៣-១៤ និង១៨ ខែដេសម ឆ្នាំ១៩២១»។*

*អស់លោក អស់អ្នក ដែលបានទៅជួបជុំក្នុងឱកាសនេះ ក៏បានចូលរួមគ្នាទះដៃទទួលគំនាប់សេចក្តីបង្ហើយនៃសេចក្តីអធិប្បាយនេះ[4]។*

( សូមរង់ចាំអានភាគបន្ត... )

---

[2] ទិសបូព៌ គឺទិសបូព៌ា។

[3] អិស្សត្រែមអូរីយ៉ង(Extrême-Orient) គឺចុងបូព៌ា។

[4] បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងកម្ពុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥, ទំព័រ៦៥-៦៨។